ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការរៀបចំការបោះឆ្នោត

# សៀវភៅណែនាំ

## គជ/ខប

សម្រាប់

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

នីតិកាលទី ៥ ឆ្នាំ ២០១៣

# មាតិកា

**ទំព័រ**

**I. គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គជ/ខប)** ........ ០១
១- សមាសភាព គធ/ខប និងលេខាធិការដ្ឋាន ........ ០១
២- ភារកិច្ច និងការទទួលខុសត្រូវរបស់ គធ/ខប ........ ០១
៣- ការប្រមូល និងការបញ្ចូលទិន្នន័យលទ្ធផលបឋមនៃការបោះឆ្នោត ដើម្បីបញ្ជូនមក គ.ជ.ប ........ ០២
ក- ការប្រមូលក្រដាសលទ្ធផលបឋមនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៥) និងរបាយការណ៍ចំនួនអ្នកសង្កេតការណ៍ ........ ០២
ខ- ការបញ្ចូលទិន្នន័យលទ្ធផលបឋមនៃការបោះឆ្នោត ........ ០៣
គ- ការបញ្ជូនលទ្ធផលបឋម និងរបាយការណ៍ចំនួនអ្នកសង្កេតការណ៍ មក គ.ជ.ប ........ ០៣
៤- មជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៅ គធ/ខប ........ ០៣
ក- ទីតាំងនៃមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផល ........ ០៣
ខ- សន្តិសុខ និងសុវត្ថិភាពនៃអគារមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផល ........ ០៤
គ- ការគ្រប់គ្រងមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផល ........ ០៤
ឃ- បម្រាម ........ ០៤
ង- ការអនុញ្ញាត ........ ០៥
៥- ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ/ខប ........ ០៥
ក- សមាសភាពក្រុមត្រួតពិនិត្យលទ្ធផល ........ ០៥
ខ- ភារកិច្ច ........ ០៥
៦- ក្រុមបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ........ ០៥
ក- សមាសភាពក្រុមបូកសរុបលទ្ធផល ........ ០៥
ខ- ភារកិច្ច ........ ០៦
គ- ការប្រើប្រាស់អ៊ីមែល ........ ០៦
៧- ការប្រគល់ ទទួលកញ្ចប់សុវត្ថិភាព " គពិសេស " កញ្ចប់ " គ " នៅមជ្ឈមណ្ឌលត្រួតពិនិត្យ នៃ គធ/ខប ........ ០៦

ក- ការប្រគល់ ........................................................................................................................ ០៦
ខ- ការទទួល ............................................................................................................................ ០៦
គ- ការចូលរួមជាសាក្សីរបស់តំណាងគណបក្សនយោបាយ ............................................................. ០៧

II. ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ទៅនឹងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់......០៧
១- អ្នកមានសិទ្ធិប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ ......................................................................... ០៧
២- ការដាក់ និងទទួលពាក្យបណ្តឹង ....................................................................................... ០៨
ក- រយៈពេលនៃការដាក់ពាក្យបណ្តឹង ................................................................................. ០៨
ខ- ការបំពេញពាក្យបណ្តឹង .................................................................................................. ០៨
គ- ពាក្យបណ្តឹងដាក់ក្រោយរយៈពេលកំណត់ ....................................................................... ០៨
ឃ- ពាក្យបណ្តឹងដែលមិនមានបញ្ជាក់ព័ត៌មានគ្រប់គ្រាន់........................................................ ០៩
ង- ពាក្យបណ្តឹងទទួលក្នុងរយៈពេលកំណត់ និងមានបញ្ជាក់ព័ត៌មានគ្រប់គ្រាន់ ................. ០៩

III. កិច្ចប្រតិបត្តិការរបស់ គឃ/ខប ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោត .............០៩
១- ការចាត់ចែង និងការរៀបចំ ............................................................................................. ០៩
ក- ការចូលរួមរបស់តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ ឬ/និងអ្នកប្តឹង......... ១០
ខ- គំរូប្លង់ កន្លែងអង្គុយ និងសម្ភាររបស់ក្រុមត្រួតពិនិត្យលទ្ធផល..................................... ១០
២- ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលគ្មានបណ្តឹង....................... ១១
ក- ដំណើរការត្រួតពិនិត្យលទ្ធផល ...................................................................................... ១១
ខ- ការពិនិត្យសម្រេចលើ ទ.១១១៦តព ............................................................................ ១២
គ- ការដាក់ឯកសារបោះឆ្នោតក្នុងកញ្ចប់ “ ឃពិសេស ” .................................................. ១៣
៣- ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែលមានបណ្តឹង.......................... ១៣
ក- ការស្នើសុំយោបល់សម្រេចពី គធ/ខប អំពីការបើក ឬមិនបើកកញ្ចប់សុវត្ថិភាព “ ក ” ... ១៣
ខ- នីតិវិធីនៃការបើកកញ្ចប់សុវត្ថិភាព “ ក ” ..................................................................... ១៤
គ- ករណីជាក់ស្តែងក្នុងការដោះស្រាយលើបណ្តឹង............................................................... ១៦

IV. ការប្រជុំសម្រេចរបស់ គឃ/ខប ............................................................................................ ១៧
១- ករណី គធ/ខប សម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ......................... ១៧
២- ករណី គធ/ខប សម្រេចព្យួរជាបណ្តោះអាសន្នលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ.............. ១៨
៣- ការបញ្ជូនសម្រង់សេចក្តីសម្រេចបដិសេធលទ្ធផលនៃការបោះឆ្នោតទៅ គ.ជ.ប ................................ ២០
ក- ស្រោមសំបុត្រធំ ............................................................................................................ ២០
ខ- កញ្ចប់ “ ឃ ព្យួរលទ្ធផល ”............................................................................................... ២១

**V. ការបំពេញលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត** .................... ២២

១- ការបំពេញតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) ក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៨) .................... ២២

២- ការប្រើប្រាស់ ទ.១១១០ ទ.១១១១ និង ទ.១១១៨ .................... ២៣

ក- តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) .................... ២៣

ខ- កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) .................... ២៣

គ- ក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៨) .................... ២៤

**VI. ការវេចខ្ចប់ និងបញ្ជូនលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត និងរាល់សម្ភារ ឯកសារ** .................... ២៤

១- កញ្ចប់ " យពិសេស " .................... ២៥

២- កញ្ចប់ " យ " .................... ២៦

ក- កញ្ចប់ “ យ ” គ្មានបណ្តឹង ឬ/និងមានបណ្តឹង “ ពិនិត្យរួច ” .................... ២៦

ខ- កញ្ចប់ “ យ ” មានបណ្តឹង/បើកកញ្ចប់សុវត្ថិភាព “ ក ” .................... ២៧

គ- ការសរសេរលេខរៀងសម្គាល់កញ្ចប់ “ យ ” .................... ២៨

ឃ- សម្ភារ ឯកសារបោះឆ្នោតនៅសល់ .................... ២៩

៣- ការចូលរួមជាសាក្សីរបស់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ .................... ២៩

**ឧបសម្ព័ន្ធ** .................... ៣០

# អក្សរកាត់

- គ.ជ.ប : គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- គធ/ខប : គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត
- គឃ/សប : គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត
- គកប : គណៈកម្មការការិយាល័យបោះឆ្នោត
- គករ : គណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត
- គកប/គករ : គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត
- ច.ប.ត.រ : ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- ប.ន.ត.រ : បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- ទ. : ទម្រង់បែបបទលេខ

# គោលបំណង

ក្នុងគោលបំណងឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ នាថ្ងៃអាទិត្យ ទី២៨ ខែកក្កដា ឆ្នាំ២០១៣ ប្រព្រឹត្តទៅរលូន ត្រឹមត្រូវតាម ច.ប.ត.រ និង ប.ន.ត.រ គ.ជ.ប បានរៀបចំចងក្រងសៀវភៅណែនាំ គធ/ខប ដើម្បីណែនាំដល់មន្ត្រីពាក់ព័ន្ធនឹងការងារនេះ រៀបចំ គ្រប់គ្រង និងឱ្យអនុវត្តតាមតួនាទី ភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ទាន់ពេលវេលា និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

សៀវភៅណែនាំនេះ ជាសេចក្តីពន្យល់ បច្ចេកទេស បទប្បញ្ញត្តិ និងគោលការណ៍លើចំណុចសំខាន់ៗនៃសកម្មភាពការងារដែល គធ/ខប ត្រូវអនុវត្ត ។

គធ/ខប ត្រូវយកចិត្តទុកដាក់សិក្សាស្វែងយល់ តាមខ្លឹមសារសៀវភៅណែនាំនេះ ដើម្បីតម្រង់ទិសដៅ រៀបចំចាត់ចែង និងអនុវត្តការងាររៀបចំការបោះឆ្នោតនៅក្នុងរាជធានី ខេត្តរបស់ខ្លួនឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព ទាន់ពេលវេលា និងសម្រេចបានជោគជ័យ ។

## I. គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ/ខប)

គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត គឺជាគណៈកម្មការគ្រប់គ្រងការបោះឆ្នោតនៅថ្នាក់រាជធានី ខេត្តដែលតែងតាំងដោយ គ.ជ.ប ដើម្បីជាជំនួយក្នុងការធ្វើផែនការ រៀបចំ ចាត់ចែង គ្រប់គ្រង និងត្រួតពិនិត្យដំណើរការបោះឆ្នោតក្នុងរាជធានី ខេត្តរបស់ខ្លួន ។

### ១- សមាសភាព គធ/ខប និងលេខាធិការដ្ឋាន

គធ/ខប មានសមាសភាពចំនួនប្រាំពីរ (៧) រូប ដែលមានប្រធាន ១ រូប អនុប្រធាន ១ រូប និងសមាជិក ៥ រូប ។ គធ/ខប មានលេខាធិការដ្ឋានមួយដែលមានផ្នែកជំនាញ ចំនួនប្រាំ (៥) ។ គធ/ខប បែងចែកសមាជិករបស់ខ្លួនឱ្យទទួលបន្ទុកការងារ ដូចខាងក្រោម ៖

- ប្រធាន មានភារៈទទួលខុសត្រូវការងាររួម ។
- អនុប្រធាន ជាជំនួយឱ្យប្រធាន និងទទួលភារៈជំនួសប្រធាន ពេលប្រធានអវត្តមាន ។
- សមាជិក ១ រូប ទទួលបន្ទុកផ្នែកប្រតិបត្តិការ ។
- សមាជិក ១ រូប ទទួលបន្ទុកផ្នែករដ្ឋបាល ។
- សមាជិក ១ រូប ទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ ។
- សមាជិក ១ រូប ទទួលបន្ទុកផ្នែកបណ្តុះបណ្តាល និងព័ត៌មានសាធារណៈ ។
- សមាជិក ១ រូប ទទួលបន្ទុកផ្នែកសេវាកម្មច្បាប់ និងវិវាទកម្ម ។

### ២- ភារកិច្ច និងការទទួលខុសត្រូវរបស់ គធ/ខប

**គធ/ខប ត្រូវ ៖**

- ចាត់គ្រប់វិធានការចាំបាច់ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅ ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។
- អនុវត្តផែនការមេ គ្រប់គ្រងថវិការបស់ខ្លួន ចុះបញ្ជី និងថែរក្សាបញ្ជីសារពើភ័ណ្ឌនៃសម្ភារ បរិក្ខារសម្រាប់ការបោះឆ្នោត និងគោរពតាមប្រតិទិននៃការបោះឆ្នោត ។
- លើកសំណើសុំតែងតាំងសមាជិក គឃ/សប សមាជិក គកប/គករ ។
- គោរព និងអនុវត្ត ច.ប.ត.រ ប.ន.ត.រ និងគោលការណ៍ណែនាំរបស់ គ.ជ.ប ។
- ចាត់វិធានការពាក់ព័ន្ធទៅនឹងសន្តិសុខ និងសណ្តាប់ធ្នាប់នៅក្នុងដំណើរការបោះឆ្នោត ។
- តាមដានការងារគ្រប់គ្រង និងប្រតិបត្តិការរបស់ គឃ/សប ។
- លើកគម្រោងជូន គ.ជ.ប អំពីចំនួន និងទីតាំងការិយាល័យបោះឆ្នោត ។
- បែងចែកសម្ភារ បរិក្ខារសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងសម្ភារបរិក្ខារបោះឆ្នោតទៅក្រុមប្រឹក្សាឃុំ សង្កាត់ និង គឃ/សប ។

- រៀបចំចាត់ចែងប្រមូលលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្តរបស់ខ្លួន និងបិទផ្សាយលទ្ធផលនៃការបោះឆ្នោតនៅក្នុងរាជធានី ខេត្តនីមួយៗរបស់ខ្លួន និងរៀបចំខ្ចប់បញ្ជូនសម្ភារបោះឆ្នោតមក គ.ជ.ប ។
- ត្រួតពិនិត្យយុទ្ធនាការឃោសនាបោះឆ្នោតនៅតាមរាជធានី ខេត្ត ។
- ចាត់គ្រប់វិធានការ ដើម្បីធានាឱ្យមានភាពស្មើគ្នាក្នុងការប្រើប្រាស់ទីសាធារណៈដល់ គណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះទាំងអស់ ក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត ។
- ចែកចាយរាល់ឯកសារ និងព័ត៌មានដែលពាក់ព័ន្ធទៅនឹងដំណើរការបោះឆ្នោត ។
- លើកគម្រោង និងអនុវត្តកម្មវិធីបណ្ដុះបណ្ដាល ស្ដីពីការបោះឆ្នោតក្នុងក្របខ័ណ្ឌរាជធានី ខេត្ត ដោយយោងតាមការណែនាំរបស់ គ.ជ.ប ។
- លើកកម្ពស់ការយល់ដឹងរបស់សាធារណជន អំពីដំណើរការបោះឆ្នោត ដោយធ្វើការសហការ និងសម្របសម្រួលការងារអប់រំអ្នកបោះឆ្នោត ក្នុងក្របខ័ណ្ឌរាជធានី ខេត្តជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ច និងអង្គការមិនមែនរដ្ឋាភិបាល ។
- អនុវត្តដំណើរការកម្មវិធីផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការបោះឆ្នោត ។
- ទទួលពាក្យបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ និងដំណើរការដោះស្រាយពាក្យបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។
- ដោះស្រាយរាល់វិវាទកម្មក្រោមសមត្ថកិច្ចរបស់ខ្លួន ដូចបានកំណត់ក្នុង ច.ប.ត.រ និង ប.ន.ត.រ ។
- ចាត់គ្រប់វិធានការដើម្បីទប់ស្កាត់ និងដោះស្រាយរាល់ភាពមិនប្រក្រតីក្នុងដំណើរការបោះឆ្នោត ។
- ដឹកនាំអនុគណៈកម្មការសន្តិសុខនៅក្នុងរាជធានី ខេត្តរបស់ខ្លួន ។
- រាយការណ៍ជូន គ.ជ.ប អំពីស្ថានភាពទូទៅក្នុងរាជធានី ខេត្តដើម្បីចាត់វិធានការធានាឱ្យការបោះឆ្នោតបានប្រព្រឹត្តទៅ ដោយសេរី និងត្រឹមត្រូវ ។
- ផ្ដល់បណ្ណសម្គាល់ជូនអ្នកសង្កេតការណ៍ជាតិ ។
- វាយតម្លៃ អំពីប្រសិទ្ធភាពការងាររបស់សមាជិកទាំងឡាយនៃ គឃ/សប ។
- អនុវត្តការងារដទៃទៀត ដែល ច.ប.ត.រ អនុញ្ញាត ឬតម្រូវឱ្យអនុវត្ត ។
- អនុវត្តការងារ ឬសិទ្ធិអំណាចដទៃទៀត ដែលត្រូវបានប្រគល់ឱ្យដោយ គ.ជ.ប ។

## ៣- ការប្រមូល និងការបញ្ចូលទិន្នន័យលទ្ធផលបឋមនៃការបោះឆ្នោត ដើម្បីបញ្ជូនមក គ.ជ.ប

### ក- ការប្រមូលក្រដាសលទ្ធផលបឋមនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៤) និងរបាយការណ៍ចំនួនអ្នកសង្កេតការណ៍

នៅពេលល្ងាច ឬយប់នៃថ្ងៃបោះឆ្នោត គឃ/ខប ត្រូវរង់ចាំទទួលក្រដាសលទ្ធផលបឋមនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៥) ដែលភ្ជាប់មកជាមួយនូវ ទ.១១០៤ និងទទួល

របាយការណ៍ចំនួនអ្នកសង្កេតការណ៍ដែលភ្ជាប់មកជាមួយនូវ ទ.១១២០ ពី គឃ/សប ដោយផ្ទាល់ ឬតាមរយៈគ្រូបង្ហាត់ប្រចាំក្រុង ស្រុក ខណ្ឌ ។

**ខ- ការបញ្ចូលទិន្នន័យលទ្ធផលបឋមនៃការបោះឆ្នោត**

នៅពេលដែល គធ/ខប ទទួលបាន ទ.១១០៥ និង ទ.១១០៨ ពី គឃ/សប រួចហើយ គធ/ខប ត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់តួលេខក្នុង ទ.១១០៥ ជាមួយផលបូកសរុបនៃតួលេខក្នុង ទ.១១០៨ ពាក់ព័ន្ធចំណុះឃុំសង្កាត់នីមួយៗ រួចបញ្ចូលទិន្នន័យលទ្ធផលបឋមនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដោយបញ្ជាក់ច្បាស់ចំនួនការិយាល័យបោះឆ្នោត ដែលបានទទួលក្រដាសលទ្ធផល ទៅក្នុងតារាងលទ្ធផលបឋមនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) ដែលមានកម្មវិធីស្រាប់ក្នុងកុំព្យូទ័រ ។

គធ/ខប ក៏ត្រូវពិនិត្យផ្ទៀងផ្ទាត់របាយការណ៍ចំនួនអ្នកសង្កេតការណ៍តាមឃុំ សង្កាត់ជាមួយនឹង ទ.១១២០ ព្រមទាំងបូកសរុបរាយការណ៍ជូន គ.ជ.ប ស្របពេលគ្នានឹងការបញ្ជូន ទ.១១១០ ដែរ ។

**គ- ការបញ្ជូនលទ្ធផលបឋម និងរបាយការណ៍ចំនួនអ្នកសង្កេតការណ៍មក គ.ជ.ប**

តារាងលទ្ធផលបឋមនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) និងរបាយការណ៍ចំនួនអ្នកសង្កេតការណ៍ត្រូវបញ្ជូនមក គ.ជ.ប (នាយកដ្ឋានប្រតិបត្តិការ) តាមរយៈអ៊ីមែលឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន គឺនៅពេលល្ងាច ឬយប់នៃថ្ងៃបោះឆ្នោត ។

**ចំណាំ** គធ/ខប ត្រូវធ្វើបច្ចុប្បន្នភាពលទ្ធផលបឋមនៃការបោះឆ្នោត និងចំនួនអ្នកសង្កេតការណ៍ក្នុងរាជធានី ខេត្ត និងបញ្ជូនលទ្ធផលនោះជាបន្ទាន់មក គ.ជ.ប ។

## ៤- មជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៅ គធ/ខប

គធ/ខប ត្រូវបង្កើតមជ្ឈមណ្ឌលមួយសម្រាប់ត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តរបស់ខ្លួន ដើម្បីផ្ញើជូន គ.ជ.ប ពិនិត្យសម្រេចជាលទ្ធផលបោះឆ្នោតផ្លូវការ។

**ក- ទីតាំងនៃមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផល**

មជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តនីមួយៗ អាចមានទីតាំងនៅលេខាធិការដ្ឋាន គធ/ខប ឬនៅអគារមួយផ្សេង ឬផ្នែកមួយនៃអគារដែលមានទំហំធំទូលាយល្មមអាចរៀបចំឱ្យមានកន្លែងបម្រុង ដូចខាងក្រោម ៖

- កន្លែងសម្រាប់ទទួលកញ្ចប់ “ គពិសេស ” និង “ គ ” ពីគ្រប់ឃុំ សង្កាត់ចំណុះរាជធានី ខេត្តពាក់ព័ន្ធដែលត្រូវស្ថិតនៅក្បែរផ្លូវចូល ។
- បន្ទប់មួយទូលាយល្មម ដែលអាចរក្សាទុកកញ្ចប់ “ គពិសេស ” និងកញ្ចប់ “ គ ” ដែលដាក់ដោយឡែកពីគ្នាតាមឃុំ សង្កាត់នីមួយៗ ក្នុងរាជធានី ខេត្ត និងមានសរសេរសម្គាល់លេខកូដឃុំ សង្កាត់នីមួយៗផង ។
- បន្ទប់មួយដោយឡែកសម្រាប់ដាក់សម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ដែល គឃ/សប បានប្រគល់ឱ្យ ។
- បន្ទប់ធំទូលាយមួយ ឬបន្ទប់តូចៗច្រើន បំពាក់ដោយតុ និងកៅអីគ្រប់គ្រាន់សម្រាប់ប្រើក្នុងពេលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត និងដែល

អាចទទួលបានទាំងសមាសភាពក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមបូកសរុបលទ្ធផល របស់ គធ/ខប ទាំងតំណាងគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍ និងអ្នកប្តឹងពាក់ព័ន្ធ ឬតំណាង ។

- បន្ទប់ស្អាតតូចមួយ (ប្រសិនបើអាច) សម្រាប់ដាក់កុំព្យូទ័រមួយគ្រឿង បំពាក់ដោយកម្មវិធី និងទម្រង់ឯកភាពមួយ សម្រាប់បញ្ចូលទិន្នន័យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត និងមានភ្ជាប់ប្រព័ន្ធអ៊ីមែល ដើម្បីបញ្ជូនលទ្ធផលទៅ គ.ជ.ប ។

**ខ- សន្តិសុខ និងសុវត្ថិភាពនៃអគារមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផល**

គធ/ខប ត្រូវធានាអំពីសន្តិសុខ និងសុវត្ថិភាពនៃអគារមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផល ។

| | |
|---|---|
| - សណ្តាប់ធ្នាប់ខាងក្នុងត្រូវមានមន្ត្រីម្នាក់ទទួលបន្ទុក ។ | |
| - មាត់ទ្វារចេញចូលត្រូវមានមន្ត្រីម្នាក់ប្រចាំការ ។ | |
| - ទ្វារ និងបង្អួចទាំងអស់ត្រូវបិទ និងចាក់សោយ៉ាងត្រឹមត្រូវនៅពេលផុតម៉ោងធ្វើការ ។ | |
| - បរិវេណសន្តិសុខត្រូវ | • មានខ្សែក្រវាត់ខាងក្រៅការពារដោយកងកម្លាំងសន្តិសុខរបស់ការិយាល័យសន្តិសុខបោះឆ្នោតរាជធានី ខេត្ត ។<br>• មានខ្សែក្រវាត់ខាងក្នុងការពារដោយកងកម្លាំងសន្តិសុខរបស់ គធ/ខប ។ |

**គ- ការគ្រប់គ្រងមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផល**

- គធ/ខប ត្រូវទទួលបន្ទុកគ្រប់គ្រងការចេញចូលមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផល និងមានសិទ្ធិ អំណាចចេញចូលមជ្ឈមណ្ឌលនេះ ។
- ជនគ្រប់រូបដែលមានវត្តមានក្នុងបរិវេណសន្តិសុខ និងក្នុងមជ្ឈមណ្ឌលត្រូវតែស្ថិតក្រោមការគ្រប់គ្រង និងការណែនាំរបស់ប្រធាន គធ/ខប ។

**ឃ- បម្រាម**

| | |
|---|---|
| - ហាមចូលក្នុងមជ្ឈមណ្ឌល : | អ្នកដែលគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប ។ |
| - សកម្មភាពត្រូវហាមឃាត់នៅក្នុងមជ្ឈមណ្ឌល | • ការស្លៀកពាក់ ការដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបេក្ខជននៃគណបក្សនយោបាយណាមួយ ។<br>• ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពលធ្វើឱ្យមន្ត្រីត្រួតពិនិត្យ និងបូកសរុបលទ្ធផលអនុវត្តភារកិច្ចដោយលំអៀង ឬបំពេញចិត្ត ឬប្រឆាំងនឹងគណបក្សនយោបាយ ឬបេក្ខជននៃគណបក្សនយោបាយណាមួយ ។ |

ង- ការអនុញ្ញាត

ត្រូវបានអនុញ្ញាតឱ្យចូលក្នុងមជ្ឈមណ្ឌលនូវជនទាំងឡាយណា ដូចខាងក្រោម ៖

- មន្ត្រីក្នុងក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមបូកសរុបលទ្ធផលនៃ គធ/ខប ។
- តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ អ្នកយកព័ត៌មាន និងអ្នកប្តឹង ឬតំណាង ។
- ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះនៅពេលដែលប្រធាន ឬតំណាង គធ/ខប សំណូមពរក្នុងករណីចាំបាច់ ។
- មន្ត្រីនៃ គ.ជ.ប ដែលចាត់ឱ្យបំពេញភារកិច្ច ឬមន្ត្រីនៃ គធ/ខប ដែលចាត់ឱ្យជួយក្នុងដំណើរការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តនោះ ។

## ៥- ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ/ខប

គធ/ខប ត្រូវតែងតាំងក្រុមមួយចំនួន យោងទៅតាមចំនួនតិច ឬច្រើននៃឃុំ សង្កាត់ក្នុងរាជធានី ខេត្តនីមួយៗ ដើម្បីត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ចំណុះរាជធានី ខេត្ត ។

ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗ ត្រូវមានសមត្ថភាពអាចត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់យ៉ាងតិចចំនួនដប់ (១០) និងអាចបែងចែកឱ្យទទួលបន្ទុកឃុំ សង្កាត់ ក្នុងក្រុង ស្រុក ខណ្ឌមួយ ឬលើសពីមួយ ។

### ក- សមាសភាពក្រុមត្រួតពិនិត្យលទ្ធផល

សមាសភាពក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ/ខប ៖

- ត្រូវជ្រើសតាំងក្នុងចំណោមសមាជិក និងមន្ត្រីនៃ គធ/ខប ក្នុងនោះត្រូវយកចិត្តទុកដាក់ចំពោះមន្ត្រីណាដែលពេលនោះមិនសូវមានការងារមមាញឹក ដូចជាគ្រូបង្អាត់ជាដើម ។
- អាចជាសមាជិក គឃ/សឃ ដែលស្ថិតនៅជិតលេខាធិការដ្ឋាន គធ/ខប (ក្នុងករណីពុំមានមន្ត្រីបុគ្គលិក គធ/ខប គ្រប់គ្រាន់ ) ។
- សមាសភាពក្រុមមានចំនួនបួន (៤) រូប គឺ ៖
    - ប្រធាន មួយ (១) រូប (ជាសមាជិក ឬមន្ត្រី គធ/ខប) ។
    - អនុប្រធាន មួយ (១) រូប ។
    - លេខាធិការ មួយ (១) រូប ។
    - ជំនួយការ មួយ (១) រូប ។

### ខ- ភារកិច្ច

ភារកិច្ចរបស់ក្រុមត្រួតពិនិត្យលទ្ធផលមានដូចតទៅ ៖

- ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែលក្រុមទទួលបន្ទុក ។
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់នេះ ជូនប្រធាន គធ/ខប ។

## ៦- ក្រុមបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត

### ក- សមាសភាពក្រុមបូកសរុបលទ្ធផល

ក្រុមបូកសរុបលទ្ធផលនេះ ត្រូវមានសមាសភាព ដូចតទៅ ៖

- ប្រធាន គធ/ខប ដែលត្រូវទទួលបន្ទុកដឹកនាំក្រុមបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តដោយផ្ទាល់ ។

- សមាជិក គធ/ខប ទទួលបន្ទុករដ្ឋបាល មួយ (១) រូប ។
- សមាជិក គធ/ខប ទទួលបន្ទុកប្រតិបត្តិការ មួយ (១) រូប ។
- មន្ត្រីដែលចេះប្រើប្រាស់កុំព្យូទ័រ មួយចំនួនតាមការចាំបាច់ ។
- ការីកុំព្យូទ័រ ឬជាមន្ត្រីដែលចេះប្រើប្រាស់ អ៊ីមែល មួយ (១) រូប ។

ខ- ភារកិច្ច

ភារកិច្ចរបស់ក្រុមបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តមានដូចតទៅ ៖

- ចាត់ចែងគណនាដោយដៃ និងម៉ាស៊ីនគិតលេខនូវលទ្ធផលនៃការបោះឆ្នោតពីគ្រប់ឃុំ សង្កាត់ ទន្ទឹមគ្នានេះបញ្ចូលលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ទាំងនោះ ទៅក្នុងតារាងលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) ដែលជាកម្មវិធីមានស្រាប់ក្នុងកុំព្យូទ័រ ។
- ផ្ទៀងផ្ទាត់លទ្ធផលដែលបានមកពីវិធីគណនាទាំងពីរ ប្រសិនបើត្រឹមត្រូវហើយ ផ្អែកលើតួលេខក្នុង ទ.១១១០ ត្រូវបំពេញ ទ.១១១១ ហើយផ្អែកលើ ទ.១១១១ ត្រូវបំពេញ ទ.១១១៤ ។
- ទ.១១១០ ទ.១១១១ និង ទ.១១១៤ ត្រូវចុះហត្ថលេខាដោយសមាជិកទទួលបន្ទុករដ្ឋបាល និងប្រធាន គធ/ខប ។

គ- ការប្រើប្រាស់អ៊ីមែល

- ប្រព័ន្ធអ៊ីមែលដែល គ.ជ.ប ផ្ដល់ជូន គធ/ខប ត្រូវប្រើប្រាស់សម្រាប់តែការបញ្ជូនសារលិខិតស្នាម ព័ត៌មានបន្ទាន់ របាយការណ៍ និងទិន្នន័យបច្ចេកទេសក្នុងការបោះឆ្នោតប៉ុណ្ណោះ ។

## ៧- ការប្រគល់ ទទួលកញ្ចប់ " គពិសេស " កញ្ចប់ " គ " នៅមជ្ឈមណ្ឌលត្រួតពិនិត្យ នៃ គធ/ខប

ក- ការប្រគល់

នៅពេលដឹកជញ្ជូនកញ្ចប់ " គពិសេស " កញ្ចប់ " គ " និងកញ្ចប់ដាក់សម្ភារ ឯកសារបោះឆ្នោតផ្សេងទៀតមកដល់ គធ/ខប ភ្លាម ប្រធាន គឃ/សប ត្រូវប្រគល់ជូនមន្ត្រីទទួលបន្ទុកការទទួលសម្ភារ ឯកសារនៃ គធ/ខប នូវ ៖

- កញ្ចប់ " គពិសេស " និង ទ.១១០៧ ពាក់ព័ន្ធ
- កញ្ចប់ " គ " និង ទ.១១០៧ ពាក់ព័ន្ធ
- កញ្ចប់សម្ភារ ឯកសារផ្សេងទៀត និង ទ.១១០៧ ពាក់ព័ន្ធ

ខ- ការទទួល

នៅពេលទទួលកញ្ចប់ " គពិសេស " កញ្ចប់ " គ " និងកញ្ចប់សម្ភារ ឯកសារ មន្ត្រីទទួលបន្ទុកការទទួលសម្ភារ ឯកសារ នៃ គធ/ខប ត្រូវធានាថា ៖

- កញ្ចប់ " គពិសេស " កញ្ចប់ " គ " និងកញ្ចប់សម្ភារ ឯកសារត្រូវបានពិនិត្យផ្ទៀងផ្ទាត់ត្រឹមត្រូវ ដោយផ្អែកលើ ទ.១១០៧ នៃកញ្ចប់ពាក់ព័ន្ធដោយមិនចាំបាច់បើកកញ្ចប់ " គពិសេស " និងកញ្ចប់ " គ " ឡើយ ។
- បានកត់ត្រាមុខសម្ភារ ឯកសារ ដែលបានទទួលទាំងអស់ក្នុងបញ្ជីទទួលសម្ភារ ឯកសាររបស់ខ្លួនរួចចារសម្គាល់ថា " ការប្រគល់ទទួលគ្រប់ចំនួន " ។

- បានចុះហត្ថលេខាលើ ទ.១១០៧ ដើម្បីបញ្ជាក់ថា បានទទួលគ្រប់ចំនួនហើយ រួចចាត់ចែងប្រើប្រាស់ ដូចខាងក្រោម ៖

ទ.១១០៧
- ប្រគល់មួយ (១) ច្បាប់ ជូនប្រធាន គឃ/សប វិញ ។
- ថតចម្លងមួយ (១) ច្បាប់ ទុកជាឯកសារនៅ គជ/ខប
- ដាក់មួយ (១) ច្បាប់ ក្នុងហោប៉ៅកញ្ចប់វិញ ។

- កញ្ចប់ " គពិសេស " កញ្ចប់ " គ " និងកញ្ចប់ដាក់សម្ភារ ឯកសារផ្សេងទៀតត្រូវបានយកទៅរក្សាទុកដោយឡែកពីគ្នាក្នុងបន្ទប់ស្តុក ដោយមានសរសេរលេខកូដឃុំ សង្កាត់នីមួយៗផង ។
- បានស្រង់កត់ត្រាឈ្មោះ និងលេខកូដឃុំ សង្កាត់ណាដែលមានកញ្ចប់ " គ " មួយ ឬច្រើនត្រូវបានសរសេរសម្គាល់ថា " មានបណ្តឹង/បើកកញ្ចប់សុវត្ថិភាព " ក " រួចចារបន្ថែមលើបញ្ជីទទួលសម្ភារ ឯកសាររបស់ខ្លួនថា " មានបណ្តឹង/បើកកញ្ចប់សុវត្ថិភាព ក " ។ បន្ទាប់មកត្រូវយកកញ្ចប់ " គពិសេស " និងកញ្ចប់ " គ " មានបណ្តឹងទាំងនោះទៅរក្សាទុកដោយឡែកក្នុងបន្ទប់ស្តុកដើម្បីងាយស្រួលរក ។
- បានរាយការណ៍ជូនប្រធាន គជ/ខប អំពីចំនួនកញ្ចប់ " គពិសេស " កញ្ចប់ " គ " និងកញ្ចប់សម្ភារ ឯកសារនៅសល់ ដែលបានទទួលពីគ្រប់ឃុំ សង្កាត់ចំណុះរាជធានី ខេត្ត និងឈ្មោះ និងលេខកូដឃុំ សង្កាត់ដែលមានបណ្តឹងជូនប្រធាន គជ/ខប ដើម្បីកំណត់បែងចែក និងណែនាំក្រុមត្រួតពិនិត្យលទ្ធផលឲ្យត្រួតពិនិត្យលទ្ធផលទៅតាមករណីជាក់ស្តែងនីមួយៗ ។

**គ- ការចូលរួមជាសាក្សីរបស់តំណាងគណបក្សនយោបាយ**

តំណាងគណបក្សនយោបាយពាក់ព័ន្ធអាចចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សីលើលិខិតប្រគល់ ទទួល ។ ការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃលើលិខិតប្រគល់ ទទួលពីតំណាងគណបក្សនយោបាយ មិនអាចចាត់ទុកលិខិតនេះជាមោឃៈបានឡើយ ។

## II. ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់នៅនឹងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយ ឬច្រើនក្នុងឃុំ សង្កាត់ នៅ គជ/ខប

**១- អ្នកមានសិទ្ធិប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់**

តំណាងគណបក្សនយោបាយដែលទទួលបានការអនុញ្ញាតឱ្យសង្កេតមើលការបោះឆ្នោតក្នុងឃុំ សង្កាត់ ឬរាជធានី ខេត្តពាក់ព័ន្ធ ឬអ្នកតំណាងដែលមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់ គឃ/សប លើបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់នឹងលទ្ធផលនៃការបោះឆ្នោត ឬ/និងភាពមិនប្រក្រតីក្នុងតំបន់បោះឆ្នោត ឬក្នុងការបោះឆ្នោត និងរាប់សន្លឹកឆ្នោត មានសិទ្ធិប្តឹងតវ៉ាអំពីករណីនោះ ឬទាំងនោះទៅ គជ/ខប ។

## ២- ការដាក់ និងទទួលពាក្យបណ្តឹង

### ក- រយៈពេលនៃការដាក់ពាក្យបណ្តឹង

- ការដាក់ពាក្យបណ្តឹងត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរពីរ (២) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេចបដិសេធរបស់ គឃ/សប លើពាក្យបណ្តឹង ។
- ក្នុងរយៈពេលកំណត់ខាងលើ ប្រសិនបើ គធ/ខប មិនបានទទួលពាក្យបណ្តឹងណាមួយទេ ចាត់ទុកថាគ្មានបណ្តឹងនៅ គធ/ខប ។
- គធ/ខប ត្រូវប្រជុំសម្រេចលើបណ្តឹងក្នុងរយៈពេលយ៉ាងយូរ បី (៣) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

### ខ- ការបំពេញពាក្យបណ្តឹង

អ្នកប្តឹងត្រូវបំពេញលើពាក្យបណ្តឹង (ទ.១២០២) ចំនួន បី (៣) ច្បាប់ ដោយមានចុះហត្ថលេខា ឬផ្តិតមេដៃ និងផ្តល់ព័ត៌មានចាំបាច់មួយចំនួនដូចខាងក្រោម ៖

- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬអ្នកតំណាង ។
- លក្ខណៈសម្គាល់នៃ គឃ/សប ឬ/និងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។
- ពេលវេលានៃការកើតឡើងនូវភាពមិនប្រក្រតី ។
- កម្មវត្ថុនៃបណ្តឹង ។
- ប្រសិនបើអាចធ្វើបាន ត្រូវបញ្ជាក់អំពីមាត្រានៃ ច.ប.ត.រ ឬ ប.ន.ត.រ ដែលត្រូវបានរំលោភ ។
- មនុស្សដែលពាក់ព័ន្ធក្នុងភាពមិនប្រក្រតីនេះ ។
- ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី (ប្រសិនបើមាន) ។
- សេចក្តីអះអាងគាំទ្រ ឬភស្តុតាង ។
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងពេលហេតុការណ៍កើតឡើង (ប្រសិនបើមាន) ។

### គ- ពាក្យបណ្តឹងដាក់ក្រោយរយៈពេលកំណត់

ចំពោះពាក្យបណ្តឹង (ទ.១២០២) ដែលដាក់ក្រោយរយៈពេលកំណត់ ប្រធាន គធ/ខប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវ ៖

- ចុះពេលវេលា កាលបរិច្ឆេទនៃការទទួលលើពាក្យបណ្តឹង (ទ.១២០២) នោះ ។
- ចារបញ្ជាក់ថា “ បណ្តឹងទទួលក្រោយរយៈពេលកំណត់ ” ។
- ចុះហត្ថលេខា និងបោះត្រាលើ ទ.១២០២ ទាំងបី (៣) ច្បាប់ ។
- ជម្រាបអ្នកប្តឹង ឬតំណាងថា ពាក្យបណ្តឹងរបស់គាត់ដាក់ក្រោយរយៈពេលកំណត់ មិនអាចទទួលដោះស្រាយបានទេ ។
- ចាត់ចែងប្រើប្រាស់ ទ.១២០២ ខាងលើ ៖

ទ.១២០២ { • ជូនអ្នកប្តឹង ឬអ្នកតំណាង ១ ច្បាប់
• ផ្ញើជូន គ.ជ.ប ១ ច្បាប់
• ទុកជាឯកសារ គឃ/ខប ១ ច្បាប់ ។

### ឃ- ពាក្យបណ្តឹងដែលមិនមានបញ្ជាក់ព័ត៌មានគ្រប់គ្រាន់

ចំពោះពាក្យបណ្តឹង (ទ.១២០២) ដែលមិនមានបញ្ជាក់ព័ត៌មានគ្រប់គ្រាន់ គឃ/ខប ត្រូវ ៖

- ណែនាំអ្នកប្តឹង ឬអ្នកតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាតមិនឱ្យហួសពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាក្នុងកំណត់ហេតុ ។
- ក្នុងករណី អ្នកប្តឹងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាតតាមការកំណត់ ចារបដិសេធលើ ទ.១២០២ គ្រប់ច្បាប់ ដោយបញ្ជាក់មូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់ ។
- ចុះហត្ថលេខា និងបោះត្រា ។
- ចាត់ចែងប្រើប្រាស់ ទ.១២០២ ខាងលើ ៖

ទ.១២០២ { • ជូនអ្នកប្តឹង ឬអ្នកតំណាង ១ ច្បាប់
• ផ្ញើជូន គ.ជ.ប ១ ច្បាប់
• ទុកជាឯកសារ គឃ/ខប ១ ច្បាប់ ។

### ង- ពាក្យបណ្តឹងទទួលក្នុងរយៈពេលកំណត់ និងមានបញ្ជាក់ព័ត៌មានគ្រប់គ្រាន់

ចំពោះបណ្តឹងដែលទទួលក្នុងរយៈពេលកំណត់ និងមានបញ្ជាក់ព័ត៌មានគ្រប់គ្រាន់ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្មត្រូវ ៖

- ចុះពេលវេលា និងកាលបរិច្ឆេទនៃការទទួលបណ្តឹងលើ ទ.១២០២ ។
- ចាត់ចែងប្រើប្រាស់ ទ.១២០២ ខាងលើ

ទ.១២០២ { • ជូនអ្នកប្តឹង ឬអ្នកតំណាង ១ ច្បាប់
• បិទផ្សាយជាសាធារណៈនៅ គឃ/ខប ១ ច្បាប់
• ទុក ១ច្បាប់ សម្រាប់ប្រើក្នុងពេលប្រជុំសម្រេច ។

- ប្រាប់អ្នកប្តឹង និងអ្នកតំណាងថា គឃ/ខប នឹងប្រជុំសម្រេចលើពាក្យបណ្តឹងរបស់គាត់ បន្ទាប់ពីក្រុមត្រួតពិនិត្យលទ្ធផលបានបញ្ចប់ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត ក្នុងឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ ។
- រាយការណ៍អំពីពាក្យបណ្តឹងខាងលើជូន គឃ/ខប ជាបន្ទាន់ ។

## III. កិច្ចប្រតិបត្តិការរបស់ គឃ/ខប ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត

### ១- ការចាត់ចែង និងការរៀបចំ

នៅពេលបានទទួលកញ្ចប់ “ គពិសេស ” និងកញ្ចប់ “ គ ” នៃឃុំ សង្កាត់មួយចំនួនហើយ គធ/ខប ត្រូវចាត់វិធានការបណ្ដើរៗ ដើម្បីឱ្យក្រុមត្រួតពិនិត្យលទ្ធផលធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់នីមួយៗដែលខ្លួនទទួលបន្ទុកឱ្យរួចរាល់ឆាប់រហ័សតាមដែលអាចធ្វើបាន ។ ការត្រួតពិនិត្យលទ្ធផលត្រូវអនុវត្តទាំងចំពោះឃុំ សង្កាត់ដែលគ្មានបណ្ដឹង ទាំងចំពោះឃុំ សង្កាត់ដែលមានបណ្ដឹង ។ ផ្អែកលើលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែលបានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់រួចហើយ គធ/ខប ត្រូវចាត់ចែងការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តឱ្យរួចរាល់ដែលមិនត្រូវឱ្យហួសរយៈពេលប្រាំ (៥) ថ្ងៃ ឡើយ ដោយគិតចាប់ពីថ្ងៃដែល គឃ/សឃ បានប្រគល់កញ្ចប់ “ គពិសេស ” និងកញ្ចប់ “ គ ” នៅ គធ/ខប ។

កិច្ចប្រតិបត្តិការត្រួតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ប្រសិនបើចាប់ដំណើរការហើយ ត្រូវធ្វើឱ្យចប់ចុងចប់ដើម ដោយមិនត្រូវគិតពីពេលវេលាឡើយ ជាពិសេសចំពោះឃុំ សង្កាត់មានបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ទាក់ទងនឹងភាពមិនប្រក្រតីធ្ងន់ធ្ងរដែលតម្រូវឱ្យក្រុមត្រួតពិនិត្យលទ្ធផលបើកកញ្ចប់សុវត្ថិភាព “ ក ” មួយ ឬច្រើនដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ។

**ក- ការចូលរួមរបស់តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ ឬ/និងអ្នកប្ដឹង**

តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ឬ/និងអ្នកប្ដឹង ឬតំណាងពាក់ព័ន្ធនឹងករណីបណ្ដឹងដែលបានដាក់ក្នុងរយៈពេលកំណត់ មានសិទ្ធិចូលរួមសង្កេតមើលកិច្ចប្រតិបត្តិការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តនៅមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃ គធ/ខប ។

- តំណាងគណបក្សនយោបាយនីមួយៗ ឬអ្នកសង្កេតការណ៍នៃអង្គការនីមួយៗ ដែលប្រចាំការតាមឃុំ សង្កាត់ទាំងអស់ក្នុងរាជធានី ខេត្តអាចជ្រើសតាំងឱ្យមានតំណាងរបស់ខ្លួនមួយ (១) រូប ដើម្បីចូលរួមសង្កេតមើលកិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ/ខប ។
- តំណាងគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ ដែលត្រូវចូលរួមសង្កេតមើលកិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ/ខប នីមួយៗ អាចផ្លាស់ប្ដូរតំណាងបម្រុងឱ្យបំពេញភារកិច្ចជំនួសខ្លួន ។
- តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ត្រូវបានរៀបចំឱ្យស្ថិតនៅទីជិតល្មមដែលអាចសង្កេតមើលឃើញនូវសកម្មភាពទាំងឡាយនៃការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ។

**ខ- គំរូប្លង់កន្លែងអង្គុយ និងសម្ភាររបស់ក្រុមត្រួតពិនិត្យលទ្ធផល**

- ក្រុមត្រួតពិនិត្យលទ្ធផលអាចអនុវត្តការងាររបស់ខ្លួនក្នុងបន្ទប់ធំទូលាយមួយ ឬបន្ទប់តូចៗច្រើន ។
- ប្លង់អង្គុយ និងសម្ភារ




## ២- ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលគ្មានបណ្ដឹង

### ក- ដំណើរការត្រួតពិនិត្យលទ្ធផល

ក្នុងដំណើរការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែលគ្មានបណ្ដឹង ប្រធានក្រុមត្រួតពិនិត្យលទ្ធផលត្រូវ ៖

- បង្គាប់ជំនួយការឱ្យយកកញ្ចប់ “ គពិសេស ” នៃឃុំ សង្កាត់ដែលគ្មានបណ្ដឹងម្ដងមួយៗ មកដាក់លើតុ ចំពីមុខប្រធាន ។
- បើកកញ្ចប់ “ គពិសេស ” រួចដកយកមកដាក់លើតុនូវ ៖
  - ស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ផ្ញើជូន គធ/ខប ។
  - រាល់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) តាមការិយាល័យក្នុងឃុំ សង្កាត់ផ្ញើជូន គធ/ខប ។
- ដកយកចេញពីកញ្ចប់ “ គពិសេស ” ទៅជូនប្រធាន គធ/ខប ដើម្បីប្រមូលដាក់ក្នុងកញ្ចប់ “ ឃពិសេស ” នូវស្រោមសំបុត្រដាក់កំណត់ហេតុនៃការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ផ្ញើជូន គ.ជ.ប ។
- ដាក់កញ្ចប់ “ គពិសេស ” ក្បែរខ្លួនគាត់ ។
- ចាត់ចែងសមាជិកក្នុងក្រុមឱ្យត្រួតពិនិត្យ និងគណនាផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់នោះ ដោយផ្អែកលើ ទ.១១០៣ និង ទ.១១០៩ ។
- ក្នុងករណី មានភាពមិនច្បាស់លាស់ ផ្ទៀងផ្ទាត់បន្ថែមជាមួយនឹង ទ.១១០១ និង ទ.១១០២ នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

- ធានាថា ៖
  - អនុប្រធាន និងលេខាធិការបានបំពេញតារាងត្រួតពិនិត្យលទ្ធផល ( ទ.១១១៦តព ) ចំនួនពីរ (២) ច្បាប់ ហើយត្រូវបានផ្ទៀងផ្ទាត់ត្រឹមត្រូវដូចគ្នា និងត្រូវមានបញ្ជាក់ឈ្មោះ និងលេខកូដឃុំ សង្កាត់ពាក់ព័ន្ធ។
  - ទ.១១១៦តព មានបញ្ជាក់ខ្លឹមសារដូចខាងក្រោម ប្រសិនបើបានរកឃើញថា ៖
    - តួលេខលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលបានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ មានភាពត្រឹមត្រូវ ។
    - គឃ/សប មានកំហុសក្នុងការត្រួតពិនិត្យ និងគណនាលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់នោះ ហើយកំហុសនោះត្រូវបានកែតម្រូវដោយក្រុមត្រួតពិនិត្យលទ្ធផល ។
- ក្នុងករណី គឃ/សប មានកំហុសក្នុងការគណនាលទ្ធផលដែលកត់ត្រាក្នុង ទ.១១០៣ និង ទ.១១០៩ ត្រូវកែតម្រូវតាមរបៀបដូចខាងក្រោម ៖
  - បង្ហាញកំហុសនិងការកែតម្រូវកំហុសព្រមទាំងហេតុផលនៃការកែតម្រូវនេះ ចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន ។
  - គូសឆូតលើតួលេខដែលខុស ដោយរក្សាលក្ខណៈដើមនៃតួលេខនោះ ។
  - សរសេរតួលេខថ្មីក្បែរនោះ ។
  - ចុះហត្ថលេខា ។

**ចំណាំ**

- តំណាងគណបក្សនយោបាយមានសិទ្ធិប្ដឹងតវ៉ា ឬ/និងប្ដឹងជំទាស់ទៅ គធ/ខប ក្នុងករណីមិនពេញចិត្តនឹងការកែតម្រូវរបស់ប្រធានក្រុមត្រួតពិនិត្យលទ្ធផល ។
- ធានាថា ទ.១១១៦តព ត្រូវបានចុះហត្ថលេខាដោយសមាសភាពទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផលពាក់ព័ន្ធ ។
- ធានាថា ទ.១១១៦តព ត្រូវបានដាក់ភ្ជាប់ទៅនឹងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ដែលដាក់ក្នុងស្រោមសំបុត្រដែលត្រៀមដាក់ជូន គធ/ខប ពិនិត្យសម្រេច ។

**ខ- ការពិនិត្យសម្រេចលើ ទ.១១១៦តព**

គធ/ខប ត្រូវពិនិត្យសម្រេចលើតារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៦តព) របស់ក្រុមត្រួតពិនិត្យលទ្ធផល ។ ប្រសិនបើពិនិត្យឃើញថាត្រឹមត្រូវហើយ ប្រធាន គធ/ខប ត្រូវ ៖

- ចារយល់ព្រមរួចចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទលើ ទ.១១១៦តព ទាំងពីរ (២) ច្បាប់ ។

- ដាក់បង្ហាញ ទ.១១១៦តព ចំពោះតំណាងគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន ។
- ត្រៀម ទ.១១១៦តព មួយ (១) ច្បាប់ផ្ញើជូន គ.ជ.ប ដែលនឹងត្រូវដាក់ក្នុងកញ្ចប់ " យពិសេស " ។
- ជូនក្រុមបូកសរុបលទ្ធផលនូវ ទ.១១១៦តព មួយ (១) ច្បាប់ និងសំណុំឯកសារភ្ជាប់ជាមួយដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន ។
- ដាក់ក្នុងកញ្ចប់ " គពិសេស " ដើម្បីរក្សាទុកជាឯកសាររបស់ គធ/ខប មាន ៖
  - ទ.១១១៦តព មួយ (១)ច្បាប់
  - ទ.១១០៣ និង ទ.១១០៩ នៃឃុំ សង្កាត់ពាក់ព័ន្ធ
  - ទ.១១០១ និង ទ.១១០២ នៃការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ

**គ- ការដាក់ឯកសារបោះឆ្នោតក្នុងកញ្ចប់ " យពិសេស "**

នៅរៀងរាល់កិច្ចប្រតិបត្តិការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗ ត្រូវប្រគល់ជូនប្រធាន គធ/ខប នូវស្រោមសំបុត្រមានដាក់ ទ.១១០៣ និង ទ.១១០៩ (ផ្ញើជូន គ.ជ.ប) សម្រាប់ប្រមូលដាក់ក្នុងកញ្ចប់ " យពិសេស " ដែលត្រៀមបម្រុងស្រាប់ ។

## ៣- ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែលមានបណ្តឹង

ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ/ខប ក៏ត្រូវត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែរ ក្នុងករណីឃុំ សង្កាត់នោះ ៖

- មានបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ដាក់នៅ គឃ/សប ។
- មានកញ្ចប់សុវត្ថិភាព " ក " មួយ ឬច្រើនត្រូវបានបើក ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតនៅ គឃ/សប ។
- មានសេចក្តីសម្រេច (ទ.១២០៣) របស់ គឃ/សប យល់ព្រម ឬបដិសេធលើបណ្តឹងនោះ ។
- មានបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ត្រូវបានដាក់នៅ គធ/ខប ។

**ក- ការស្នើសុំយោបល់សម្រេចពី គធ/ខប អំពីការបើក ឬមិនបើកកញ្ចប់សុវត្ថិភាព " ក "**

ក្នុងការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែលមានបណ្តឹង ក្រុមត្រួតពិនិត្យលទ្ធផលត្រូវ ៖

- ត្រួតពិនិត្យជាមុននូវ ៖
  - ទ.១២០៣ របស់ គឃ/សប លើបណ្តឹងពាក់ព័ន្ធ ។
  - របាយការណ៍របស់ គឃ/សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ។
  - ទ.១២០២ ដាក់នៅ គធ/ខប ។

- ស្នើសុំយោបល់សម្រេចពី គធ/ខប អំពីការអនុញ្ញាតឱ្យបើក ឬមិនឱ្យបើកកញ្ចប់សុវត្ថិភាព " ក " នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

ផ្អែកតាមឯកសារ និងការស្នើសុំយោបល់ដែលក្រុមត្រួតពិនិត្យលទ្ធផលបានដាក់ជូន គធ/ខប ៖

- ក្នុងករណីគ្មានភាពមិនប្រក្រតីធ្ងន់ធ្ងរ គធ/ខប ៖
  - ➔ មិនតម្រូវឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ឡើយ ។
  - ➔ ឱ្យក្រុមត្រួតពិនិត្យលទ្ធផលអនុវត្តការងារ ដូចការត្រួតពិនិត្យលទ្ធផល ករណីឃុំ សង្កាត់គ្មានបណ្ដឹង ។
- ក្នុងករណីមានភាពមិនប្រក្រតីធ្ងន់ធ្ងរដែលនាំឱ្យប៉ះពាល់លទ្ធផលនៃការបោះឆ្នោតក្នុង ឃុំ សង្កាត់ពាក់ព័ន្ធ គធ/ខប ៖
  - ➔ ត្រូវសម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ។
  - ➔ ឱ្យក្រុមត្រួតពិនិត្យ អនុវត្តតាម III.២.ក និង III.២.គ រួចអនុវត្តនីតិវិធីបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ( III.៣.ខ ) ។

**ខ- នីតិវិធីនៃការបើកកញ្ចប់សុវត្ថិភាព " ក "**

- **ការបើកកញ្ចប់សុវត្ថិភាព " ក "**

ប្រធានក្រុមត្រួតពិនិត្យលទ្ធផលត្រូវ ៖

- បង្គាប់ជំនួយការឱ្យទៅនាំយកកញ្ចប់ " គ " នៃឃុំ សង្កាត់ពាក់ព័ន្ធ មកដាក់នៅលើតុចំពីមុខប្រធានក្រុម ។
- កាត់សោឃ្លុំបើកកញ្ចប់ " គ " បន្ទាប់មក ៖
  - ដកយកកញ្ចប់ " ខ " ចេញមកក្រៅ ។
  - បើកកញ្ចប់ " ខ " រួចដកយកកញ្ចប់សុវត្ថិភាព " ក " មកដាក់លើតុ ។
- បើកកញ្ចប់សុវត្ថិភាព " ក " រួចដកយករាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតទាំងអស់ ដែលមាននៅខាងក្នុងមកដាក់ដោយឡែកពីគ្នាលើតុខាងមុខគាត់ ។
- ប្រគល់ ទ.១១០១ ទ.១១០២ និង ទ.១១០៨ ទៅឱ្យលេខាធិការ សម្រាប់តាមដានពិនិត្យដោយប្រៀបធៀបទៅនឹងលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ។
- បើកស្រោមសំបុត្រ ឬស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតម្ដងមួយៗ រួចចាត់ចែងត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតនៅការិយាល័យ

នោះ ដោយយកចិត្តទុកដាក់ចំពោះបញ្ហាក្នុងកម្មវត្ថុនៃបណ្តឹងពាក់ព័ន្ធ និងបញ្ហាដូចខាងក្រោម ៖

- ពិនិត្យផ្ទៀងផ្ទាត់លេខកូដការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។
- ពិនិត្យផ្ទៀងផ្ទាត់ត្រាសម្ងាត់បោះលើខ្នងសន្លឹកឆ្នោត នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។
- ពិនិត្យ និងរាប់ចំនួនអ្នកបានមកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ។
- ពិនិត្យផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត និងលេខរៀងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រគល់ឱ្យការិយាល័យបោះឆ្នោតនោះ ជាមួយលេខរៀងគល់បញ្ជីសន្លឹកឆ្នោតដែលទទួលពីការិយាល័យបោះឆ្នោតនោះវិញ ។
- រាប់ចំនួនសន្លឹកឆ្នោតខូច (ប្រសិនបើមាន) ។
- រាប់ចំនួនសន្លឹកឆ្នោតមិនបានប្រើ ។
- ពិនិត្យ និងរាប់សន្លឹកឆ្នោតមិនបានការ ។
- ពិនិត្យនិងរាប់ចំនួនសន្លឹកឆ្នោតបានការ ដែលបានបោះគាំទ្រគណបក្សនយោបាយនីមួយៗ ។

▪ អនុវត្តតាមលំនាំនីតិវិធីដដែលក្នុងការបើកកញ្ចប់សុវត្ថិភាព “ ក ” ដើម្បីផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត សម្រាប់កញ្ចប់សុវត្ថិភាព “ ក ” នីមួយៗ ក្នុងករណី គធ/ខប សម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព “ ក ” នៃការិយាល័យបោះឆ្នោតលើសពីមួយ ។

- **របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព “ ក ”**

បន្ទាប់ពីបានបើកកញ្ចប់សុវត្ថិភាព “ ក ” នៃការិយាល័យបោះឆ្នោតណាមួយដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរួចរាល់ហើយ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលត្រូវចាត់ចែង ៖

▪ ធ្វើរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព “ ក ” ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតចំនួនពីរ (២) ច្បាប់ ដោយក្នុងនោះត្រូវ ៖

- លើកយោបល់ស្នើសុំ គធ/ខប ពិនិត្យសម្រេច
  + យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ។ ឬ
  + ព្យួរជាបណ្តោះអាសន្នលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ដោយត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ។
- ចុះហត្ថលេខាដោយសមាសភាពទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផល ។

- ចារលើរបាយការណ៍របស់ គឃ/សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព “ ក ” ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (ប្រសិនបើមាន) ដោយបញ្ជាក់ខ្លឹមសារស្របទៅនឹងរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផល ។
- ដាក់ជូន គធ/ឧប ពិនិត្យសម្រេចនូវ ៖
    - តារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៦តព)  ពីរ (២) ច្បាប់ ។
    - ទ.១១០៣ និង ទ.១១០៩ ។
    - របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព “ ក ” របស់ក្រុមត្រួតពិនិត្យលទ្ធផល ពីរ (២ )ច្បាប់
    - ទ.១២០៣ របស់ គឃ/សប និង របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព “ ក ” របស់ គឃ/សប (ប្រសិនបើមាន) ។
- ដាក់សម្ភារ ឯកសារបោះឆ្នោតទៅក្នុងស្បោងប្លាស្ទិក និងស្រោមសំបុត្រពាក់ព័ន្ធនានា រួចវេចខ្ចប់កញ្ចប់សុវត្ថិភាព “ ក ” វិញ តាមលំនាំដើម ។
- ដាក់កញ្ចប់សុវត្ថិភាព “ ក ” ទៅក្នុងកញ្ចប់ “ ខ ” រួចចងភ្ជិតកញ្ចប់ “ ខ ” ។
- ដាក់កញ្ចប់ “ ខ ” ទៅក្នុងកញ្ចប់ “ គ ” នៃឃុំ សង្កាត់មានបណ្តឹងពាក់ព័ន្ធតាមលំនាំដើម និងរក្សាទុកនៅកន្លែងដើម ត្រៀមវេចខ្ចប់ និងបញ្ជូនទៅ គ.ជ.ប ។

- **ការដោះស្រាយបណ្តឹង**

គធ/ឧប ត្រូវប្រជុំសម្រេចដោះស្រាយលើបណ្តឹងដែលបានដាក់នៅ គធ/ឧប ដោយផ្អែកលើ ៖

- តារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៦តព)
- កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) និង តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩)
- របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព “ ក ” របស់ក្រុមត្រួតពិនិត្យលទ្ធផល
- សេចក្តីសម្រេច (ទ.១២០៣) របស់ គឃ/សប លើបណ្តឹងពាក់ព័ន្ធ
- របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព “ ក ” របស់ គឃ/សប (ប្រសិនបើមាន)
- ពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ដែល គធ/ឧប បានទទួល ។

**គ- ករណីជាក់ស្តែងក្នុងការដោះស្រាយលើបណ្តឹង**

គធ/ឧប ត្រូវប្រជុំសម្រេចលើបណ្តឹងនីមួយៗទៅតាមករណីជាក់ស្តែង នៃពេលវេលាក្នុងការទទួលពាក្យបណ្តឹង ។

- ក្នុងករណីពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ត្រូវបានដាក់នៅ គធ/ឧប នៅក្រោយពេលដែលក្រុមត្រួតពិនិត្យលទ្ធផលបានធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត នៅឃុំ សង្កាត់ពាក់ព័ន្ធនឹងបណ្តឹងនោះរួចហើយតាមករណីឃុំ សង្កាត់មានបណ្តឹង គធ/ឧប ត្រូវផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យរួចហើយនោះ ដើម្បីប្រជុំសម្រេចលើពាក្យបណ្តឹងពាក់ព័ន្ធ ។

- ក្នុងករណីពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ត្រូវបានដាក់នៅ គធ/ខប នៅក្រោយពេលដែលក្រុមត្រួតពិនិត្យលទ្ធផលបានធ្វើការត្រួតពិនិត្យលទ្ធផល នៃការបោះឆ្នោតដែលពាក់ព័ន្ធនឹងបណ្តឹងនោះរួចហើយតាមករណីឃុំ សង្កាត់គ្មានបណ្តឹង ប្រសិនបើ គធ/ខប សម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព "ក" គធ/ខប ត្រូវធានាថា ក្រុមត្រួតពិនិត្យបានអនុវត្តនីតិវិធីត្រួតពិនិត្យលទ្ធផលតាមករណីឃុំ សង្កាត់មានបណ្តឹងជាបន្ថែមទៀតនៅមុនពេល គធ/ខប សម្រេចលើពាក្យបណ្តឹង ។
- ក្នុងករណីមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ពាក់ព័ន្ធនឹងឃុំ សង្កាត់ដែលពុំទាន់បានត្រួតពិនិត្យ គធ/ខប ត្រូវធានាថា ក្រុមត្រួតពិនិត្យបានអនុវត្តនីតិវិធីត្រួតពិនិត្យលទ្ធផលតាមករណីឃុំ សង្កាត់មានបណ្តឹងនៅមុនពេល គធ/ខប សម្រេចលើពាក្យបណ្តឹង ។

## IV. ការប្រជុំសម្រេចរបស់ គធ/ខប

### ១- ករណី គធ/ខប សម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យណាមួយក្នុងឃុំ សង្កាត់

ប្រសិនបើ គធ/ខប សម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ប្រធាន គធ/ខប ត្រូវ ៖

- ចារយល់ព្រមទទួលយកលទ្ធផល រួចចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទលើ ៖
  - តារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៦គ៣) ចំនួនពីរ (២)ច្បាប់ ។
  - របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " របស់ក្រុមត្រួតពិនិត្យលទ្ធផលចំនួនពីរ (២)ច្បាប់ ។
  - របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " របស់ គឃ/សប (ប្រសិនបើមាន) និងថតចម្លងមួយ (១)ច្បាប់ ដាក់ក្នុងកញ្ចប់ " គពិសេស " ។
